# សេចក្តីថ្លែងការណ៍

ភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៨

នៅលើពិភពលោកមានមនុស្សរាប់លាននាក់ កំពុងជួបនឹងបញ្ហាសន្តិសុខស្បៀង ។ នៅប្រទេសកម្ពុជា ក៏មានចំនួនប្រជាជនជាច្រើនសែនគ្រួសារកំពុងប្រឈមនឹងបញ្ហានេះដែរ ជាពិសេសក្នុងឆ្នាំ ២០០៨ ដោយសារតម្លៃអង្ករមានការឡើងថ្លៃ ហើយលទ្ធភាពប្រាក់ចំណូលនៅមានកំរិត ។ ទន្ទឹមនឹងនេះ យើងក៏មានការបារម្ភណ៍ដែរថា បញ្ហានេះអាចនៅតែបន្តទៅមុខទៀត ប្រសិនបើគ្មានដំណោះស្រាយសមស្របណាមួយ ។

ក្នុងឱកាសទិវាអ្នកអត់ស្បៀងអាហារពិភពលោក ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៨ នេះ យើងសូមផ្តល់ជាអនុសាសន៍ក៏ដូចជាការអំពាវនាវសំខាន់ៗ ដូចខាងក្រោមនេះដល់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធៈ

១- គាំទ្រ និងពង្រីកនូវការងារផ្សព្វផ្សាយប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ( ប.វ.ស. SRI ) ឱ្យបានទូទាំងប្រទេសគ្រប់ភូមិ ឃុំ ស្រុក ដើម្បីឱ្យកសិករអ្នកធ្វើស្រែគ្រប់រូបមានឱកាសបានរៀនសូត្រ និងអនុវត្តតាម

២- បង្កើន និងពង្រីកនូវសមត្ថភាពកសិករ ក្នុងការផលិត និងទុកដាក់ពូជស្រូវនៅតាមសហគមន៍

៣- ជម្រុញនូវការផលិត និងប្រើប្រាស់ជីធម្មជាតិ អោយបានទូលំទូលាយ

៤- ពង្រឹង និងពង្រីកការវិនិយោគទុន លើការស្តារ និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងពង្រឹងសមត្ថភាពសហគមន៍ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ជាពិសេសផ្តោតលើប្រព័ន្ធខ្នាតតូច និងមធ្យម

៥- បង្កើនសមត្ថភាពសហគមន៍ក្នុងការស្តុកស្រូវទុក ជាពិសេសសមត្ថភាពចងក្រងសហគមន៍ និងផ្តល់ទុនប្រាក់កម្ចីដែលមានការប្រាក់ទាប

៦- បញ្ជ្រាបដល់ការបណ្តុះបណ្តាលអំពីកសិកម្មនៅក្នុងកម្មវិធីអប់រំជនបទ ជាពិសេសចាប់ពីថ្នាក់ទី ៩ ឡើងទៅ ដើម្បីផ្តល់ឱកាសដល់សិស្សដែលចាប់អារម្មណ៍លើមុខរបរកសិកម្ម ងាយស្រួលក្នុងការចាប់យកជំនាញ ។

៧- ពង្រឹងឱកាសទីផ្សារជូនដល់កសិករដើម្បីអាចពួកគាត់ងាយស្រួលក្នុងការលក់ផលិតផលបានតំលៃ សមរម្យ និងចាត់វិធានការណ៍សមស្របលើការនាំចូលនូវផលិតផលមួយចំនួនដែលអាចផលិតក្នុងស្រុក

៨- ផ្តល់លទ្ធភាពលើការទុកដី សម្រាប់ធ្វើសម្បទានសង្គមកិច្ច ជាជាងធ្វើសម្បទានសេដ្ឋកិច្ច

៩- បង្កើនការភ្ញាក់រលឹក អោយបានទូលំទូលាយដល់កសិករ និងអជ្ញាធរមូលដ្ឋាន ក្នុងគោលបំណងជំរុញ កុំអោយមានការលក់ដីស្រែ ។